# ពាក្យថា នមោ តេ
# និងការនមស្ការព្រះពុទ្ធ

*(ធម្មសប្បាយរបស់ខ្ញុំ)*

**នមត្ថុ រតនត្តយស្ស**

*កិរិយានមស្ការនៃខ្ញុំ សូមមានចំពោះប្រជុំបីនៃវត្ថុ ជាគ្រឿងត្រេកអររបស់ពួកជនអ្នកត្រូវការព្រះនិព្វាន*

**អរហំ សម្មាសម្ពុទ្ធោ ភគវា** *ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកកិលេសហើយ ត្រាស់ដឹងនូវព្រះធម៌ទាំងពួងដោយប្រពៃនិងដោយព្រះអង្គឯង,* **ពុទ្ធំ ភគវន្តំ អភិវាទេមិ** *ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ហើយ។*

**ស្វាក្ខាតោ ភគវតា ធម្មោ** *ព្រះធម៌ ដែលព្រះមានព្រះភាគសម្ដែងប្រពៃហើយ,* **ធម្មំ នមស្សាមិ** *ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌។*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ,* **សង្ឃំ វន្ទាមិ** *ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃ។*

## មហានមស្ការ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស,

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស,

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

កិរិយានមស្ការនៃខ្ញុំ សូមមានចំពោះព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកកិលេសហើយ ត្រាស់ដឹងនូវព្រះធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង។

## អគ្គប្បសាទសូត្រ

ខ្ញុំបានស្តាប់មកថា ព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់សម្តែងហើយ ព្រះអរហន្តទ្រង់សម្តែងហើយថា ៖

តយោមេ ភិក្ខវេ អគ្គប្បសាទា។ កតមេ តយោ?

ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរនេះមាន ៣វត្ថុ។ វត្ថុ៣ គឺអ្វីខ្លះ?

យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា ចតុប្បទា វា ពហុប្បទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អ-សញ្ញិនោ វា នេវសញ្ញិនាសញ្ញិនោ វា, តថាគតោ តេសំ អគ្គមក្ខាយតិ អរហំ សម្មាសម្ពុទ្ធោ។ យេ ភិក្ខវេ ពុទ្ធេ បសន្នា, អគ្គេ តេ បសន្នា; អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងអម្បាលម៉ាន ដែលជាសត្វមិនមានជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរ ជាងពួកសត្វទាំងអម្បាលនោះ។ ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា ជ្រះថ្លា ក្នុងព្រះពុទ្ធ, ជនទាំងឡាយនោះ ឈ្មោះថាជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ; ឯផលដ៏ប្រសើរ រមែងមានដល់ជនទាំងឡាយដែលជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ។

យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា វា, វិរាគោ តេសំ អគ្គមក្ខាយតិ យទិទំ មទនិម្មទនោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ។ យេ ភិក្ខវេ ធម្មេ បសន្នា, អគ្គេ តេ បសន្នា; អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ។

ម្នាលភិក្ខុទាំងឡាយ ពួកធម៌ទាំងអម្បាលម៉ាន ដែលមានបច្ច័យប្រជុំតាក់តែងក្តី មិនមានបច្ច័យប្រជុំតាក់តែងក្តី វិរាគធម៌ គឺធម៌ដែលញាំញីសេចក្តីស្រវឹង កម្ចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ដកចេញឡើងនូវសេចក្តីអាល័យក្នុង

កាម ចូលទៅកាត់ផ្តាច់នូវវដ្តៈ ជាទីអស់ទៅនៃតណ្ហា ប្រាសចាកតម្រេក រលត់តណ្ហាមិនមានសេសសល់ មិនមានវានៈគឺតណ្ហា ប្រាកដជាប្រសើរ ជាងធម៌ទាំងអម្បាលនោះ។ ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា ជ្រះថ្លាក្នុងព្រះធម៌, ជនទាំងឡាយនោះ ឈ្មោះថាជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ; ឯផលដ៏ប្រសើររមែងមានដល់ជនទាំងឡាយ ដែលជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ។

យាវតា ភិក្ខវេ សង្ឃា វា គណា វា, តថាគតសាវ-កសង្ឃោ តេសំ អគ្គមក្ខាយតិ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុ-នេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណី-យោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស។ យេ ភិក្ខវេ សង្ឃេ បសន្នា, អគ្គេ តេ បសន្នា; អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសង្ឃក្តី ពួកគណៈក្តីទាំងអម្បាលម៉ាន សង្ឃជាសាវ័កនៃតថាគត ប្រាកដជាប្រសើរជាងពួកសង្ឃនិងគណៈទាំងអម្បាលនោះ ព្រះសង្ឃសាវ័ក នៃព្រះមានព្រះភាគ បើរាប់ជាគូនៃបុរសមាន៤គូ បើរាប់រៀងជា

បុរសបុគ្គលមាន៨ពួក លោកគួរទទួលយកនូវបច្ច័យ៤ លោកគួរទទួលនូវទានដែលគេរៀបចំដើម្បីភ្ញៀវ លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា លោកគួរទទួលនូវអញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ លោកជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក។ ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា ជ្រះថ្លាក្នុងព្រះសង្ឃ ជនទាំងឡាយនោះឈ្មោះថាជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរ។ ឯផលដ៏ប្រសើរ រមែងមានដល់ជនទាំងឡាយ ដែលជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ។

**ឥមេ ខោ ភិក្ខវេ តយោ អគ្គប្បសាទា។**

ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ មាន ៣វត្ថុនេះឯង។

ព្រះមានព្រះភាគ ទ្រង់បានត្រាស់សូត្រនេះហើយ ទ្រង់ត្រាស់គាថាពន្ធ ក្នុងសូត្រនេះដូច្នេះទៀតថា

អគ្គតោ វេ បសន្នានំ, អគ្គំ ធម្មំ វិជានតំ;
អគ្គេ ពុទ្ធេ បសន្នានំ, ទក្ខិណេយ្យេ អនុត្តរេ ។
អគ្គេ ធម្មេ បសន្នានំ, វិរាគូបសមេ សុខេ;
អគ្គេ សង្ឃេ បសន្នានំ, បុញ្ញក្ខេត្តេ អនុត្តរេ ។
អគ្គស្មឹ ទានំ ទទតំ, អគ្គំ បុញ្ញំ បវឌ្ឍតិ;

អគ្គំ អាយុ ច វណ្ណោ ច, យសោ កិត្តិ សុខំ ពលំ។
អគ្គស្ស ទាតា មេធាវី, អគ្គធម្មសមាហិតោ;
ទេវភូតោ មនុស្សោ វា, អគ្គប្បត្តោ បមោទតិ ។

កាលជនទាំងឡាយ ដែលជ្រះថ្លាក្នុងព្រះរតនត្រ័យដ៏ប្រសើរ ដែលដឹងច្បាស់នូវធម៌ដ៏ប្រសើរ ដែលជ្រះថ្លា ក្នុងព្រះពុទ្ធជាបុគ្គលដ៏ប្រសើរលើសលប់ ជាទក្ខិណេយ្យ-បុគ្គល រកអ្នកឯណាមួយឲ្យស្មើនឹងព្រះអង្គគ្មាន ដែលជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌ប្រាសចាកតម្រេក និងស្ងប់រំងាប់នូវកិលេសទាំងអស់ ជាសុខ ព្រោះការអស់ទៅនៃវដ្តទុក្ខនិងការស្ងប់រំងាប់នូវសង្ខារ ដែលជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យ រកស្រែបុណ្យឯទៀតឲ្យក្រៃលែងជាងគ្មាន ដែលជាអ្នកឲ្យនូវទាន ដល់ព្រះរតនត្រ័យដ៏ប្រសើរ បុណ្យដ៏ប្រសើរ រមែងចម្រើន អាយុដ៏ប្រសើរផង សម្បុរកាយដ៏ប្រសើរផង យសសក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែងចម្រើន។ បុគ្គលមានប្រាជ្ញា ដែលមានចិត្តតម្កល់ទុក ក្នុងធម៌ដ៏ប្រសើរហើយ ជា អ្នកឲ្យនូវទានដល់ព្រះរតនត្រ័យដ៏ប្រសើរ តែងនឹង

បានទៅហើយជាទេវតាឬមនុស្ស ក៏រមែងបានដល់នូវភាវៈជាអ្នកប្រសើរ ហើយរីករាយសប្បាយ ។

សេចក្ដីនេះឯង ព្រះមានព្រះភាគទ្រង់សម្ដែងហើយ គឺខ្ញុំបានស្ដាប់មកហើយ យ៉ាងនេះឯង ។

(បិដក៥៣ ទំព័រ១១៦)

{គាថាទាំងឡាយថា **អគ្គតោ វេ បសន្នានំ** ជាដើម មានក្នុងបិដក លេខ៤២ ទំព័រ ៨៦ ផង បិដកលេខ៤៥ ទំព័រ៧១ ផង បិដកលេខ ៥៣ ទំព័រ១១៨}

# ជយឃោស

## ការប្រកាសជ័យជម្នះ

ពួកនាគ គ្រុឌ ទេវតា និងព្រហ្ម មានគ្រឿងក្រអូបនិងផ្កាកម្រងជាដើមក្នុងដៃ បានទៅកាន់ពោធិបល្ល័ង្ក សម្នាក់ព្រះមហាបុរស បានថ្វាយព្រះពរជ័យ ដូចគាថាព័ន្ធពោលទុកថា៖

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ,
មារស្ស ច បាបិមតោ បរាជយោ;
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា,
ជយំ តទា នាគគណា មហេសិនោ។

ក្នុងកាលនោះ ពួកនាគទាំងឡាយ មានចិត្តសប្បាយ បានស្រែកប្រកាស នូវជ័យជម្នះ របស់ព្រះមហេសី នាពោធិមណ្ឌដ្ឋាន (យ៉ាងនេះថា) ព្រះពុទ្ធដ៏មានសិរីទ្រង់ឈ្នះមារហើយ, មារមានចិត្តបាបចាញ់ព្រះអង្គហើយ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ,
មារស្ស ច បាបិមតោ បរាជយោ;
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា,
ជយំ តទា សុបណ្ណសង្ឃា មហេសិនោ។

ក្នុងកាលនោះ ពួកគ្រុឌទាំងឡាយ មានចិត្តសប្បាយ បានស្រែកប្រកាស នូវជ័យជម្នះ របស់ព្រះមហេសី នាពោធិមណ្ឌដ្ឋាន (យ៉ាងនេះថា) ព្រះពុទ្ធដ៏មានសិរីទ្រង់ឈ្នះមារហើយ, មារមានចិត្តបាបចាញ់ព្រះអង្គហើយ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ,
មារស្ស ច បាបិមតោ បរាជយោ;
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា,
ជយំ តទា ទេវគណា មហេសិនោ។

ក្នុងកាលនោះ ពួកទេវតាទាំងឡាយ មានចិត្តសប្បាយ បានស្រែកប្រកាស នូវជ័យជម្នះ របស់ព្រះមហេសី នាពោធិមណ្ឌដ្ឋាន (យ៉ាងនេះថា) ព្រះពុទ្ធដ៏មានសិរីទ្រង់ឈ្នះមារហើយ,

មារមានចិត្តបាបចាញ់ព្រះអង្គហើយ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ,
មារស្ស ច បាបិមតោ បរាជយោ;
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា,
ជយំ តទា ព្រហ្មគណា មហេសិនោ។

ក្នុងកាលនោះ ពួកព្រហ្មទាំងឡាយ មានចិត្តសប្បាយ បានស្រែកប្រកាស នូវជ័យជម្នះ របស់ព្រះមហេសី នាពោធិមណ្ឌដ្ឋាន (យ៉ាងនេះថា) ព្រះពុទ្ធដ៏មានសិរីទ្រង់ឈ្នះមារហើយ, មារមានចិត្តបាបចាញ់ព្រះអង្គហើយ។

ពួកទេវតា ក្នុងម៉ឺនចក្កវាឡដទៃទៀត កាលនាំគ្នាមកបូជាដោយគ្រឿងក្រអូប ផ្កាកម្រង និងគ្រឿងលាបផ្សេងៗ ក៏បានឈរពោលសរសើរ មានប្រការ
ផ្សេងៗ (ដោយបីតិនិងបញ្ញា របស់ខ្លួន) ។

(ជាតកដ្ឋកថា អដ្ឋកថាជាតក,
វិសុទ្ធជនវិលាសិនី អដ្ឋកថាអបទាន, នមក្ការដីកា)

ឥឡូវនេះ យើងខ្ញុំព្រះអង្គទាំងឡាយ មានចិត្តសប្បាយ បាននាំយក វត្ថុទាំងឡាយ មានផ្កាកម្រង គ្រឿងក្រអូប ... យកមកបូជាថ្វាយ ចំពោះព្រះអង្គ ក្នុងទីនេះ ហើយសូមស្រែកប្រកាស នូវជ័យជម្នះ របស់ព្រះមហេសី តាមបទបាលី ដែលពួកនាគគ្រុឌទេវតានិងព្រហ្មទាំងឡាយ ពោលថ្វាយព្រះពរជ័យ ក្នុងកាលណោះ យ៉ាងនេះថា៖ ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ, មារស្ស ច បាបិមតោ បរាជយោ = ព្រះពុទ្ធដ៏

មានសិរី ទ្រង់ឈ្នះមារហើយ, មារមានចិត្តបាបចាញ់ព្រះអង្គហើយ។

ការពោលប្រកាសនូវជយឃោស មានបែបបទ មានប្រការផ្សេងៗ តាមសេចក្ដីជ្រះថ្លា តាមសមត្ថភាព របស់លោកអ្នកដឹកនាំ ។

# រឿងហ្មពស់ (អហិតុណ្ឌិកៈ)

មានសេចក្ដីដំណាលថា ក្នុងភទ្ទកប្បនេះ ព្រះសាស្ដាព្រះនាមកស្សបទសពល ទ្រង់បានត្រាស់ដឹងឡើង ក្នុងលោកមុនព្រះសមណគោតមបរមគ្រូនៃយើង ទ្រង់បានដឹកនាំមនុស្សលោក ព្រមទាំងទេវលោក (ដែលមានបុណ្យបារមីឧបនិស្ស័យនៃការត្រាស់ដឹង) ឲ្យឆ្លងផុតចាកសមុទ្ទសំសារ ទ្រង់បានសម្រេច នូវព្រះពុទ្ធកិច្ចទាំងអស់ ក៏បរិនិព្វានទៅ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងសេតព្យនគរ ដូចព្រះសុរិយាអស្ដង្គតទៅ ក្នុងទិសបច្ឆិម។ ក្នុងកាលនោះ ពួកមនុស្សអ្នកនៅក្នុងសកលជម្ពូទ្វីប បានប្រជុំគ្នាធ្វើឥដ្ឋមាសមួយដុំៗ វិចិត្រដោយរតនៈ មានតម្លៃមួយកោដិកហាបណៈ ដើម្បីកផ្នែកខាងក្រៅ ធ្វើឥដ្ឋមាស១ដុំៗ វិចិត្រដោយរតនៈមានតម្លៃកន្លះកោដិកហាបណៈដើម្បីកផ្នែកខាងក្នុង ធ្វើកិច្ចដីស្អិត ដោយមនោសិលា កសាងព្រះស្តូប កម្ពស់មួយយោជន៍ ហើយធ្វើសក្ការៈដ៏ធំក្រៃលែង។

កាលនោះ មានហ្មពស់(អហិតុណ្ឌិកៈ)ម្នាក់បានបង្វឹកពស់ឲ្យលេង ក្នុងភូមិនិគមនិងរាជធានី ចិញ្ចឹមជីវិត បានទៅដល់ភូមិមួយ បានកម្រៃរង្វាន់ ដែលពួកអ្នកភូមិមានចិត្តត្រេកអរឲ្យហើយបរិភោគខាទនីយភោជនីយាហារហើយ ក៏ស្នាក់នៅក្នុងទីនោះ។ បានឮមកថា ពួកមនុស្សក្នុងភូមិនោះ ដោយច្រើន ជាអ្នក

រាប់អានព្រះរតនត្រ័យ។ ព្រោះហេតុនោះ ពួកគាត់កាលដេកក្នុងពេលយប់ តែងពោលសរសើរព្រះរតនត្រ័យ មានពាក្យជាដើមយ៉ាងនេះថា "**នមោ ពុទ្ធាយ**" ។ ចំណែកគាត់ ជាអ្នកមិច្ឆាទិដ្ឋិ មិនដឹងគុណព្រះរតនត្រ័យ, ព្រោះហេតុនោះ គាត់ឮពាក្យនោះរបស់ពួកអ្នកភូមិ កាលធ្វើការចំអក ដោយខ្លួនឯង ក៏ចេះតែពោលថា "**នមោ ពុទ្ធាយ, នមោ ពុទ្ធាយ**" ដោយអំណាចនៃការសើចលេងនុ៎ះឯង។ តមកថ្ងៃមួយ គាត់កាលដើរស្វែងរកពស់ក្នុងទីនោះៗ ដើម្បីទុកឲ្យលេងយកលុយ។ កាលនោះ មាននាគរាជមួយ ទៅថ្វាយបង្គំព្រះស្តូប របស់ព្រះកស្សបទសពល ហើយក៏ចូលទៅក្នុងដំបូកមួយ។ គាត់ ឃើញហើយ បានទៅយ៉ាងលឿន ហើយសូធ្យសេពមន្ត ដើម្បីចាប់នាគរាជ។ ស្តេចពស់ឮមន្តនោះហើយ ខឹងក្រោធ ទើបស្ទុះទៅដេញតាមគាត់ដើម្បីសម្លាប់។ គាត់ឃើញនាគរាជដេញតាមដូច្នោះ ទើបរត់ទៅយ៉ាងលឿន ជាន់ជុំថ្មភ្លាត់ដួលទៅ ពោលថា "**នមោ ពុទ្ធាយ, នមោ ពុទ្ធាយ**" តាមការសន្សំពាក្យសើចលេង ដែលខ្លួនធ្លាប់ពោលហើយក្នុងកាលមុន។ ពាក្យពោលថា នមោ ពុទ្ធាយ របស់គាត់ បានធ្លាក់ចុះចូលកាន់រន្ធត្រចៀកនាគរាជ ដែលកំពុងតែដេញតាម ដូចសំឡេងអមតៈ។ លំដាប់នោះ នាគរាជរំលត់កំហឹងក្នុងបុរសនោះ ព្រោះសេចក្តីគោរពក្នុងព្រះរតនត្រ័យ

ហើយពោលថា "ម្នាលសម្លាញ់ អ្នកកុំខ្លាចឡើយ, យើងជាប់អន្ទាក់អ្នកហើយ ដោយអន្ទាក់គឺអានុភាព នៃមន្តព្រះរតនត្រ័យ; ព្រោះហេតុនោះ ការដែលយើងចឹកអ្នក មិនសមគួរដល់យើងឡើយ។ ថ្ងៃនេះ យើងមានសេចក្ដីជ្រះថ្លាចំពោះអ្នក, យើងសូមឲ្យបណ្ណាការដល់អ្នក, សូមអ្នកទទួលនូវសុវណ្ណបុប្ផា (ផ្កាមាស) ទាំង៣ដុំនេះចុះ"។ ឈ្មោះថា ព្រះរតនត្រ័យ តែងធ្វើចិត្តនៃពស់ដែលមានពិសដ៏ពន្លឹកឲ្យជ្រះថ្លា យ៉ាងនេះឯង។ ក្នុងរឿងនេះ មានពាក្យសរសើរព្រះរតនត្រ័យយ៉ាងនេះថា៖

ពុទ្ធោតិ វចនំ សេដ្ឋំ, ពុទ្ធោតិ បទមុត្តមំ;
នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ។

ពាក្យថាពុទ្ធោ ជាពាក្យដ៏ប្រសើរបំផុត, បទថាពុទ្ធោ ជាបទដ៏ខ្ពង់ខ្ពស់បំផុត, ពាក្យនិងបទដទៃ ដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទថាពុទ្ធោនោះ ក្នុងលោកមិនមានឡើយ។

ធម្មោតិ វចនំ សេដ្ឋំ, ធម្មោតិ បទមុត្តមំ;
នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ។

ពាក្យថាធម្មោ ជាពាក្យដ៏ប្រសើរបំផុត, បទថាធម្មោ ជាបទដ៏ខ្ពង់ខ្ពស់បំផុត, ពាក្យនិងបទដទៃ ដែលពីរោះ

ដល់ត្រចៀក ស្មើដោយពាក្យនិងបទធម្មោនោះ ក្នុងលោក មិនមានឡើយ។

សង្ខ្យាតិ វចនំ សេដ្ឋំ, សង្ខ្យាតិ បទមុត្តមំ;
នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ។

ពាក្យថាសង្ខ្យា ជាពាក្យដ៏ប្រសើរបំផុត, បទថាសង្ខ្យា ជាបទដ៏ខ្ពង់ខ្ពស់បំផុត, ពាក្យនិងបទដទៃ ដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទសង្ខ្យានោះ ក្នុងលោក មិនមានឡើយ។

តស្ស មុខំ មុខំ នាម, យំ វត្តតិ មុខេ សទា;
ទុល្លភំ ពុទ្ធវចនំ, សព្វសម្បត្តិទាយកំ។

ពាក្យថាពុទ្ធោ ជាពាក្យដែលគេពោលបានដោយកម្រ ជាពាក្យឲ្យនូវសម្បត្តិទាំងពួង តែងប្រព្រឹត្តទៅក្នុងមាត់របស់អ្នកណា សព្វៗកាល, មាត់របស់អ្នកនោះ ទើបឈ្មោះថាជាមាត់មែន។

តស្ស មនោ មនោ នាម, យំ ចេ មនសិ វត្តតិ;
ទុល្លភំ ពុទ្ធវចនំ, សព្វសម្បត្តិទាយកំ។

ពាក្យថាពុទ្ធោ ជាពាក្យដែលគេគិតបានដោយកម្រ ជាពាក្យឲ្យនូវសម្បត្តិទាំងពួង តែងប្រព្រឹត្តទៅក្នុងចិត្តរបស់

អ្នកណា (សព្វៗកាល), ចិត្តរបស់អ្នកនោះ ទើបឈ្មោះថា ជាចិត្តមែន។

តមេវ ករចំ ទេហេ, តមេវ មណិ កាមទោ;
តមេវ សុរភីធេនុ, តមេវ សុរបាទបោ។

ពាក្យថាពុទ្ធោនោះឯង ជាគ្រឿងក្រោះព្វដ៏កាយ, ពាក្យថាពុទ្ធោនោះឯង ជាកែវមណី ដែលឲ្យសម្បត្តិតាមប្រាថ្នា, ពាក្យថាពុទ្ធោនោះឯង ជាមេគោបង្ហូរទឹកដោះដែលមានក្លិនដ៏ក្រអូប, ពាក្យថាពុទ្ធោនោះឯង ជាដើមឈើដ៏ស័ក្តិសិទ្ធិ។

តស្សេវ សោតំ សោតំវ, យំ សុណាតិ ជនោ អយំ;
ទុល្លភំ ពុទ្ធវចនំ, សព្វសម្បត្តិទាយកំ។

ជន(នៅក្នុងលោក)នេះ បានឮពាក្យថាពុទ្ធោ ជាពាក្យដែលគេឮបានដោយកម្រ ជាពាក្យឲ្យនូវសម្បត្តិទាំងពួងដោយត្រចៀកណា (សព្វៗកាល), ត្រចៀកនោះ របស់ជននោះ ទើបឈ្មោះថាជាត្រចៀកមែន។

ឯវំ វិធោរគោ ឃោរោ, ហាឡាហាឡវិសោ សទា;
ពុទ្ធោតិ វចនំ សុត្វា, សន្តុដ្ឋោទាសិ ជីវិតំ។
សោណ្ណបុប្ផត្តយំ ចាបិ, មហាគ្ឃំ ពហលំ អទា;

បស្ស ពុទ្ធោតិ វាចាយ, អានុភាវមហន្តតំ។

ពស់ ជាសត្វឃោរឃៅ មានពិសដ៏ខ្លាំងក្រៃលែង សព្វ កាល មានប្រការយ៉ាងនេះ ឮពាក្យថាពុទ្ធោហើយ ជាអ្នក មានចិត្តត្រេកអរ បានឲ្យជីវិត (ដល់ហ្មពស់) ថែមទាំង បានឲ្យផ្កាមាសពជុំដ៏ធំក្រាស់ៗ ដែលមានតម្លៃច្រើន, អ្នកចូរមើលនូវអានុភាពដ៏ធំ នៃពាក្យថាពុទ្ធោចុះ។

លុះនាគរាជបានឲ្យផ្កាមាសទាំងពដុំនោះ ដល់បុរសនោះ ហើយ បានពោលយ៉ាងនេះ រួចទូន្មានថា "ម្នាលសម្លាញ់ អ្នក ចូរយកផ្កាមាសមួយដុំទៅបូជា ដើម្បីប្រយោជន៍បុណ្យដល់ អ្នក, មួយដុំទៅបូជា ដើម្បីប្រយោជន៍បុណ្យដល់ខ្ញុំ, មួយដុំ ទៀត កាលរស់នៅឲ្យជាសុខស្រួល ចិញ្ចឹមប្រពន្ធកូន មិន ប្រមាទក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ មានទានជាដើម ចិញ្ចឹម ជីវិត, ចូរជាអ្នកឈប់ខ្វល់ខ្វាយ ក្នុងអំពើថោកទាប(នេះ), និង លះបង់នូវមិច្ឆាទិដ្ឋិចោលទៅ" ហើយទើបចៀសចេញទៅ។ ឯ បុរសនោះ មានចិត្តសោមនស្សរីករាយ បូជាព្រះចេតិយ ដោយផ្កាមាសពីរដុំ តាមពាក្យដែលនាគរាជនោះប្រាប់ហើយ យកផ្កាមាសមួយដុំទៀតទៅលក់ បានលុយមួយពាន់កហាប ណៈ ចិញ្ចឹមប្រពន្ធកូន និងឲ្យទានដល់អ្នកកំព្រា អ្នកដើរផ្លូវ និងស្មូមយាចកទាំងឡាយ លះបង់អហិតុណ្ឌិកកម្ម (អំពើប

ធ្វើកពស់) សន្សំតែកុសល អស់អាយុទៅ ក៏បានជាអ្នកមាន ឋានសួគ៌ប្រព្រឹត្តទៅខាងមុខ។

ឥតិ អវិទិតសត្តោ កិញ្ចិ ពុទ្ធានុភាវំ,
លភតិ ធនវិសេសំ យស្ស នាមប្បកាសា;
វិទិតជននិកាយោ កិន្នុ តស្សានុភាវំ,
ន លបតិ ជិននាមំ កិច្ចមញ្ញប្បហាយ។

សត្វដែលមិនដឹងពុទ្ធានុភាពអ្វីតិចតួច យ៉ាងនេះ ក៏នៅតែបានទ្រព្យដ៏វិសេស ព្រោះហេតុតែការប្រកាសនូវព្រះនាមនៃពាក្យថាពុទ្ធោឯណា, ចុះពួកជនដែលដឹង នូវពុទ្ធានុភាពនៃពាក្យថាពុទ្ធោនោះ បានលះបង់នូវកិច្ចដទៃហើយ មិនប្រកាសនូវព្រះនាម របស់ព្រះជិនស្រី យ៉ាងមេចទៅ?

រឿងហ្មពស់ ចប់ ៕

(គម្ពីររសវាហិនី)

ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ!
ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ!
ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ!
ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ! ពុទ្ធោ!

**ពុទ្ធោតិ តេសំ សុត្វាន, បីតិ ឧប្បជ្ជិ តាវទេ;**

**ពុទ្ធោ ពុទ្ធោតិ កថយន្តា, តិដ្ឋន្តិ បញ្ជលីកតា។**

បីតិរបស់ជនទាំងនោះ បានកើតឡើងហើយ ព្រោះឮពាក្យថាពុទ្ធោ ក្នុងខណៈនោះឯង, ពួកជនទាំងនោះ កំពុងឈរផ្គងអញ្ជលី ពោលសរសើរថា **ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ!**។ (បិ។ ៧៧/១២)

*ពួកទេវតាឈរផ្គងអញ្ជលីពោលសរសើរព្រះពុទ្ធថា៖ **ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ!** (ខុទ្ទកនិកាយ ពុទ្ធវង្ស)

*សុមេធបណ្ឌិត កាលធ្វើផ្លូវថ្វាយព្រះពុទ្ធទីបង្ករទ្រង់គិតថា៖ **ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ!** (ខុទ្ទកនិកាយ ពុទ្ធវង្ស)

*អនាថបិណ្ឌិកសេដ្ឋី ចូលសម្រាន្តធ្វើការស្វាធ្យាយថា៖ **ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ! ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ!**

(សារត្ថទីបនី ដីកាសេនាសនក្ខន្ធកៈ,

សារត្ថបកាសិនី អដ្ឋកថាសុទត្តសូត្រ)

*ពួកជនអ្នកគិតថា ព្រះពុទ្ធជាបុគ្គលដ៏អស្ចារ្យតែងពោលថា៖ **ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ!**

(អបទាន ពុទ្ធវង្ស ព្រមទាំងអដ្ឋកថានិងដីកាជាច្រើន)

## នមោ តេ

សុគតំ សុគតំ សេដ្ឋំ, កុសលំកុសលំ ជហំ;
អមតំ អមតំ សន្តំ, អសមំ អសមំ ទទំ។
សរណំ សរណំ លោកំ, អរណំ អរណំករំ;
អភយំ អភយំ ឋានំ, នាយកំ នាយកំ នមេ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសុគត ទ្រង់មានព្រះដំណើរល្អ ទ្រង់ប្រសើរបំផុតដោយសីលាទិគុណ ទ្រង់លះបង់កុសលនិងអកុសល ទ្រង់ជាបុគ្គលមិនស្លាប់ ទ្រង់ដល់នូវព្រះនិព្វានជាគុណជាតមិនស្លាប់ ទ្រង់ស្ងប់ រំងាប់នូវកិលេសនិងវដ្តទុក្ខ ទ្រង់មិនមានបុគ្គលស្មើ ដោយសីលាទិគុណ ទ្រង់ប្រទាននូវព្រះធម៌ដែលមិនស្មើ ដោយលោកិយធម៌ ទ្រង់ជាទីរលឹកនៃសត្វលោក ទ្រង់ ជ្រាបច្បាស់នូវត្រៃលោក ទ្រង់មិនមានកិលេស ទ្រង់ធ្វើនូវការមិនមានកិលេសនោះ ក្នុងសន្តាននៃវេនេយ្យសត្វ ទ្រង់មិនមានជាតាទិភ័យ ទ្រង់ជាលោកនាយកដឹកនាំ វេនេយ្យសត្វទៅកាន់ទីមិនមានភ័យ។ (នមក្ការបាឡិអញ្ញៈ)។

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
កុសលេន សមេក្ខសិ, អមនុស្សាបិ តំ វន្ទន្តិ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការ

ចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមមនស្ការ ចំពោះព្រះអង្គ, ព្រះអង្គទ្រង់ឃើញនូវមហាជនដោយព្រះសព្វញ្ញុតញ្ញាណ មិនមានទោស សូម្បីពួកអមនុស្ស ក៏នាំគ្នានមស្ការព្រះអង្គដែរ ។ (បិ.១៩/១០០)

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
សព្វញ្ញូសិ មហាវីរ, លោកជេដ្ឋ នរាសភ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមមនស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ចម្បងក្នុងលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញូ ជ្រាបនូវរឿងសព្វគ្រប់ ។ (អាសនត្ថេរ បិ.៧៤/១៩)

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
ពហុជ្ជនំ តារយសិ, ទេសេន្តោ អមតំ បទំ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមមនស្ការ ចំពោះព្រះអង្គ, ព្រះអង្គសម្តែងនូវអមតបទ គឺព្រះនិព្វាន តែងចម្លងជនច្រើន (ឲ្យដល់នូវត្រើយគឺព្រះនិព្វាន) ។ (ថោមកត្ថេរ )

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
អត្តានំ តោសេសយិត្វាន, បរេ តោសេសិ ត្វំ មុនិ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ព្រះអង្គទ្រង់ញ៉ាំងខ្លួនព្រះអង្គឲ្យត្រេកអរហើយ ទ្រង់ញ៉ាំងពួកជនដទៃឲ្យត្រេកអរផងដែរ។ (សុមង្គលត្ថេរ បិ.៧៣/១៧)

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
ញាណេន តេ សមោ នត្ថិ, យាវតា ញាណមុត្តមំ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, សភាវៈជាគ្រឿងដឹងស្មើដោយព្រះញាណព្រះអង្គ មិនមានឡើយ, ញាណរបស់ព្រះអង្គដ៏ឧត្តម យ៉ាងក្រៃលែង។

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
សទេវកស្មិំ លោកស្មិំ, នត្ថិ តេ បដិបុគ្គលោ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូម

នមស្ការចំពោះព្រះអង្គ, ព្រះអង្គមិនមានបុគ្គលប្រៀបផ្ទឹមក្នុងលោក ព្រមទាំងទេវលោក។ (បិ.៥៧/៦៨)

តុវំ ពុទ្ធោ តុវំ សត្ថា, តុវំ មារាភិភូ មុនិ;
តុវំ អនុសយេ ឆេត្វា, តិណ្ណោ តារេសិ មំ បជំ។

ព្រះអង្គជាសព្វញ្ញុពុទ្ធ ព្រះអង្គជាគ្រូតាមបង្រៀន ព្រះអង្គជាអ្នកប្រាជ្ញ គ្របសង្កត់នូវមារទាំងអស់ ព្រះអង្គ ទ្រង់កាត់បង់នូវអនុស័យ ឆ្លង(អន្លង់ដ៏ធំគឺសំសារ ដោយព្រះអង្គឯង) ហើយ ទើបញ៉ាំងពពួកសត្វនេះ ឲ្យឆ្លងផងដែរ។

នមោ តេ ពុទ្ធ វីរត្ថុ, វិប្បមុត្តោសិ សព្វធិ;
ព្យសនម្හិ អនុប្បត្តោ, តស្ស មេ សរណំ ភវ។

បពិត្រព្រះពុទ្ធ ទ្រង់ជាវីរជន ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, ព្រះអង្គរួចផុតស្រឡះចាកកិលេសទាំងពួង, ខ្ញុំព្រះអង្គដល់នូវសេចក្តីវិនាស សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ។ (សម្បសាទិកត្ថេរ បិ.៧៤/៦)

នមោ តេ ពុទ្ធ វីរត្ថុ, វិប្បមុត្តោសិ សព្វធិ;
សម្ពាធបដិបន្នោស្មិ, តស្ស មេ សរណំ ភវ។

បពិត្រព្រះពុទ្ធ ទ្រង់ជាវីរជន ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, ព្រះអង្គរួចផុតស្រឡះចាកធម៌ទាំងពួង មានខន្ធនិង

អាយតនៈជាដើម; ខ្ញុំព្រះអង្គកំពុងដល់នូវគ្រោះដ៏ចង្អៀត, សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ។ (ចន្ទិមសូរិយ បិ.២៩/២៣២, ២៣៣)

នមោ តេ វាទិសូទន, នមោ តេ ឥសិសត្តម;

នមោ តេ សព្វលោកគ្គ, នមោ តេ អភយង្ករ។

បពិត្រព្រះអង្គទ្រង់បង្ហូរនូវពាក្យប្រៀនប្រដៅ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ជាឥសិទី៧ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុគ្គល ប្រសើរជាងសត្វលោកទាំងអស់ ខ្ញុំសូមនមស្ការចំពោះ ព្រះអង្គ, បពិត្រព្រះអង្គទ្រង់ធ្វើនូវអភ័យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ។

នមោ តេ មារមថន, នមោ តេ ទិដ្ឋិសូទន;

នមោ តេ សន្តិសុខទ, នមោ តេ សរណង្ករ។

បពិត្រព្រះអង្គ ទ្រង់ញាំញីនូវមារ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់បង្ហូរនូវពាក្យប្រៀនប្រដៅ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ប្រទាន នូវសន្តិសុខ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ធ្វើនូវទីពឹង ខ្ញុំសូមនមស្ការចំពោះព្រះអង្គ។ (បិ.៧៥/៣៧៥)

នមោ តេ សព្វទស្សាវិ, នមោ តេ ករុណាករ;

នមោ តេ តិណ្ណសំសារ, នមោ តេ អមតំ ទទ។

បពិត្រព្រះអង្គទ្រង់ឃើញនូវហេតុផលទាំងពួង ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវករុណា ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់មានសំសារឆ្លងផុតហើយ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ប្រទាននូវអមតធម៌ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ។ (ខេមាថេរីគាថា បិ.៧៦/៩០)

អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;
កទ្បេវរំ មេ បតិតំ ទេវលោកេ រមាមហំ។

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! សម្បត្តិរបស់ព្រះសាស្តា នៃយើង ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! រាងកាយរបស់ដួលចុះហើយ, ខ្ញុំបានត្រេកអរ ក្នុងទេវលោក។

(គន្ធោទកិយត្ថេរ បិដកលេខ៧២)

អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;
ពុទ្ធស្ស អានុភាវេន, វសុធាយំ បកម្បថ។

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! សម្បត្តិរបស់ព្រះសាស្តា នៃយើង ដ៏

អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ផែនដីនេះ បានកម្រើកញាប់ញ័រហើយ ដោយអានុភាពនៃព្រះពុទ្ធ។

តញ្ច អច្ឆរិយំ ទិស្វា, អព្ភុតំ លោមហំសនំ;
ពុទ្ធេ ចិត្តំ បសាទេមិ, ទ្វិបទិន្ទម្ហិ តាទិនេ។

ខ្ញុំឃើញនូវហេតុ ដ៏អស្ចារ្យ ចំឡែក គួរព្រឺរោមនោះ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ជាធំ ជាងសត្វជើងពីរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ឡើយ។

(មហាបរិវារកត្ថេរ បិដកលេខ៧៣/១៥)

អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;
យស្មិំ ឧប្បជ្ជមានម្ហិ, បថវី សម្បកម្បតិ។

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! សម្បត្តិរបស់ព្រះសាស្តា នៃយើង ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រោះកាលដែលព្រះអង្គត្រាស់ដឹង(ក្នុងលោក) សូម្បីផែនដីក៏កក្រើកញាប់ញ័រដែរ។

(ពុទ្ធសញ្ញិកត្ថេរ បិដកលេខ៧៣/២៥)

អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;
ឯកច្ចត្តស្ស ទានេន ទុគ្គតិំ នុបបជ្ជហំ។

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! សម្បត្តិរបស់ព្រះសាស្តា នៃយើង ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ខ្ញុំមិនដែលចូលទៅកើតក្នុងទុគ្គតិ ដោយការឲ្យឆត្រមួយ។ (សបរិវារឆត្តទាយកត្ថេរ បិ.៧៨)

អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;
អចេតនាបិ តុរិយា សយមេវ បវជ្ជរេ។

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! សម្បត្តិរបស់ព្រះសាស្តា នៃយើង ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! តូរ្យតន្ត្រីសូម្បីឥតចេតនាសោះ ក៏ប្រគំដោយខ្លួនឯងបានដែរ។

(បាដិហីរសញ្ញកត្ថេរ បិដកលេខ៧៥)

នត្ថិ ចិត្តេ បសន្នម្ហិ, អប្បកា នាម ទក្ខិណា;
តថាគតេ វា សម្ពុទ្ធេ, អថ វា តស្ស សាវកេ។

កាលបើចិត្តជ្រះថ្លាហើយ ក្នុងព្រះតថាគតសម្មាសម្ពុទ្ធក្តី ក្នុងសាវករបស់ព្រះអង្គក្តី ទក្ខិណា ឈ្មោះថាមានផលតិចតួចមិនឡើយ។

ឯហិ មាតលិ អម្ហេ បិ, ភិយ្យោ ភិយ្យោ មហេមសេ;
តថាគតស្ស ធាតុយោ, សុខោ បុញ្ញានមុច្ចយោ។

ម្នាលមាតលិ អ្នកចូរមក, យើងនាំគ្នាទៅបូជាព្រះសារីរិកធាតុនៃព្រះតថាគត ឲ្យក្រៃលែងឲ្យអស្ចារ្យ, ព្រោះថាការសន្សំបុណ្យ នាំមកនូវសេចក្ដីសុខ។

តិដ្ឋន្តេ និព្ពុតេ ចាបិ, សមេ ចិត្តេ សមំ ផលំ;
ចេតោបណិធិហេតុ ហិ, សត្តា គច្ឆន្តិ សុគ្គតិំ។

ព្រះមានព្រះភាគទ្រង់ធរមាននៅក៏ដោយ បរិនិព្វានទៅហើយក៏ដោយ កាលបើចិត្តស្មើ ផលក៏ស្មើ ព្រោះថាសត្វទាំងឡាយទៅកាន់សុគតិ ដោយសារតែការតម្កល់ចិត្តឲ្យល្អជាហេតុ។

ពហូនំ វត អត្ថាយ, ឧប្បជ្ជន្តិ តថាគតា;
យត្ថ ការំ ករិត្វាន, សគ្គំ គច្ឆន្តិ ទាយកា។

ឱ! ទាយកទាំងឡាយ ធ្វើនូវការបូជា ចំពោះព្រះតថាគតទាំងឡាយឯណាហើយ តែងទៅកាន់ឋានសួគ៌បាន, ព្រះតថាគតទាំងឡាយនោះ ទ្រង់កើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើនមែនហើយ។ (បីតវិមានវត្ថុ)

ពុទ្ធោ សោ ភគវា ពោធាយ ធម្មំ ទេសេតិ, ទន្តោ សោ ភគវា ទមថាយ ធម្មំ ទេសេតិ, សន្តោ សោ ភគវា

សមថាយ ធម្មំ ទេសេតិ, តិណ្ណោ សោ ភគវា តរណាយ ធម្មំ ទេសេតិ, បរិនិព្វុតោ សោ ភគវា បរិនិព្វានាយ ធម្មំ ទេសេតិ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចទាំង៤ហើយ ទ្រង់សម្ដែងធម៌ដល់សត្វទាំងឡាយ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងនូវអរិយសច្ចទាំង៤ដែរ, ព្រះមានព្រះភាគអង្គនោះ ទ្រង់ទូន្មាននូវឥន្ទ្រិយទាំង៦ហើយ ទ្រង់សម្ដែងធម៌ ដល់សត្វទាំងឡាយ ដើម្បីប្រយោជន៍ ដល់ការទូន្មាននូវឥន្ទ្រិយទាំង៦ដែរ, ព្រះមានព្រះភាគអង្គនោះ ទ្រង់ស្ងប់រំងាប់នូវកិលេសទាំងអស់ហើយ ទ្រង់សម្ដែងធម៌ដល់សត្វទាំងឡាយ ដើម្បីប្រយោជន៍ដល់ការស្ងប់រំងាប់នូវកិលេសទាំងអស់ដែរ, ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្លងផុតនូវអន្លង់ទាំង៤ហើយ ទ្រង់សម្ដែងធម៌ ដល់សត្វទាំងឡាយ ដើម្បីប្រយោជន៍ ដល់ការឆ្លងផុតនូវអន្លង់ទាំង៤ដែរ, ព្រះមានព្រះភាគអង្គនោះ ទ្រង់រំលត់នូវកិលេសទាំងអស់ហើយ ទ្រង់សម្ដែងធម៌ដល់សត្វទាំងឡាយ ដើម្បីប្រយោជន៍ដល់ការរំលត់នូវកិលេសទាំងអស់ដែរ។

(ឧទុម្ពិកសូត្រ បិ.១៨/១០៨, ចូឡសច្ចកសូត្រ បិ.២២/៨៤, វម្មិកសូត្រអដ្ឋកថា ពុទ្ធវណ្ណកថា)

# ការលាន់មាត់សរសើរ

***អប្បមាណោ ពុទ្ធោ!*** *ព្រះពុទ្ធគុណ ប្រមាណមិនបាន!*

***អប្បមាណោ ធម្មោ!*** *ព្រះធម្មគុណ ប្រមាណមិនបាន!*

***អប្បមាណោ សង្ឃោ!*** *ព្រះសង្ឃគុណ ប្រមាណមិនបាន!*

*(វិ។ចូឡ។ ១០/១៤១; អំ។ចតុក្ក។ ៤២/១៨០; ខុ។ជាតក ៥៨/១០២)*

***សាធុ ពុទ្ធស្ស សុពោធិតា!*** *សេចក្តីត្រាស់ដឹងដ៏ប្រពៃនៃព្រះពុទ្ធ ញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់សត្វទាំងឡាយ!*

***សាធុ ធម្មស្ស សុធម្មតា!*** *សេចក្តីទ្រទ្រង់ដ៏ប្រពៃនៃព្រះធម៌ ញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់សត្វទាំងឡាយ!*

***សាធុ សង្ឃស្ស សុបដិបត្តិ!*** *សេចក្តីប្រតិបត្តិដ៏ប្រពៃនៃព្រះសង្ឃ ញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់សត្វទាំងឡាយ!*

*(ពាក្យសរសើរលោកអ្នកជ្រះថ្លាក្នុងរតនត្រ័យ)*

***អហោ ពុទ្ធោ!*** *ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ!*

***អហោ ធម្មោ!*** *ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ!*

***អហោ សង្ឃោ!*** *ព្រះសង្ឃដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ!*

*(សុមង្គលវិលាសិនី ឧទានវាចាព្រះបាទពិម្ពិសារទៀបសោយទិវង្គត)*

**សម្មាសម្ពុទ្ធោ ភគវា!**

ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងនូវព្រះធម៌ទាំងពួងដោយប្រពៃនិងដោយព្រះអង្គឯងមែនហើយ!

**ស្វាក្ខាតោ ភគវតា ធម្មោ!**

ព្រះធម៌ ដែលព្រះមានព្រះភាគ

ទ្រង់សម្តែងដោយល្អមែនហើយ!

**សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ!**

ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ

លោកប្រតិបត្តិដោយល្អមែនហើយ!

(ទី.បាថិក. ១៨/២០៤, អំ.តិក. ៤១/៤៣៥, មហានិ. ៦៥/១៧៦, មិលិន្ទបញ្ហបាលី, អភិ.កថា. ៨៦/១៧០, អដ្ឋកថាដីកាជាច្រើន, ម.មូ.ចូឡហត្ថិបទោបមសូត្រ ២១/១៧០ ជាដើមមាន១៤ដង, ម.ម.ធម្មចេតិយសូត្រ ២៤/៤៧៦ ជាដើម មាន១០ដង)

លក្ខណៈចំណាំ៖ ទីឃនិកាយ អង្គុត្តរនិកាយ មហានិទ្ទេស មិលិន្ទបញ្ហបាលី អភិធម្ម កថាវត្ថុ ព្រមទាំងអដ្ឋកថានិងដីកាជាច្រើន មិនមាន ភគវតា ត្រង់ធម្មគុណ, មិនមាន ភគវតោ សាវក- ត្រង់សង្ឃគុណ។

**ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ! ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ!**

**ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ! ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ!**

ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ!

ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ!

ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ!

ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ!

**ធម្មោ ធម្មោ ធម្មោ ធម្មោ! ធម្មោ ធម្មោ ធម្មោ ធម្មោ!**

**ធម្មោ ធម្មោ ធម្មោ ធម្មោ! ធម្មោ ធម្មោ ធម្មោ ធម្មោ!**

ព្រះធម៌ ព្រះធម៌ ព្រះធម៌ ព្រះធម៌!

ព្រះធម៌ ព្រះធម៌ ព្រះធម៌ ព្រះធម៌!

ព្រះធម៌ ព្រះធម៌ ព្រះធម៌ ព្រះធម៌!

ព្រះធម៌ ព្រះធម៌ ព្រះធម៌ ព្រះធម៌!

**សង្ឃោ សង្ឃោ សង្ឃោ សង្ឃោ! សង្ឃោ សង្ឃោ សង្ឃោ សង្ឃោ!**

**សង្ឃោ សង្ឃោ សង្ឃោ សង្ឃោ! សង្ឃោ សង្ឃោ សង្ឃោ សង្ឃោ!**

ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ!

ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ!

ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ!

ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ!

**ពុទ្ធោ ពុទ្ធោ ពុទ្ធោ ពុទ្ធោ! សុភោ សុភោ សុភោ សុភោ!**

**អហោ អហោ អហោ អហោ! នមោ នមោ នមោ នមោ!**

ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ!

ល្អណាស់ ល្អណាស់ ល្អណាស់ ល្អណាស់!

អស្ចារ្យ អស្ចារ្យ អស្ចារ្យ អស្ចារ្យ!

សូមនមស្ការ សូមនមស្ការ!

**ធម្មោ ធម្មោ ធម្មោ ធម្មោ! សុភោ សុភោ សុភោ សុភោ!**

**អហោ អហោ អហោ អហោ! នមោ នមោ នមោ នមោ!**

ព្រះធម៌ ព្រះធម៌ ព្រះធម៌ ព្រះធម៌!

ល្អណាស់ ល្អណាស់ ល្អណាស់ ល្អណាស់!

អស្ចារ្យ អស្ចារ្យ អស្ចារ្យ អស្ចារ្យ!

សូមនមស្ការ សូមនមស្ការ!

**សង្ឃោ សង្ឃោ សង្ឃោ សង្ឃោ! សុភោ សុភោ សុភោ សុភោ!**

**អហោ អហោ អហោ អហោ! នមោ នមោ នមោ នមោ!**

ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ ព្រះសង្ឃ!

ល្អណាស់ ល្អណាស់ ល្អណាស់ ល្អណាស់!

អស្ចារ្យ អស្ចារ្យ អស្ចារ្យ អស្ចារ្យ!

សូមនមស្ការ សូមនមស្ការ!

**អហោ ពុទ្ធោ អហោ ធម្មោ អហោ សង្ឃោ!**

**អហោ ពុទ្ធស្ស សាសនំ!**

**អច្ឆរិយេហិ ឯតេហិ**

**សព្វទុក្ខា បមុច្ចរេ ។**

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះសង្ឃដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះពុទ្ធសាសនាដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ដ្បិតថាពួកលោកអ្នកស្រលាញ់សុខ រួចស្រលះចាកវដ្តទុក្ខទាំងពួងព្រោះវត្ថុដ៏អស្ចារ្យទាំងនេះ។

*ធម្មសប្បាយ របស់ខ្ញុំ វ៉េន ភិរម្យ*